## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ:៣១២/២៣ ក.ប/អ.ក/អ.ធ.ក/ព.ក

**ជម្រាបមក**
**លោក ម្ចាស់ ឬនាយកក្រុមហ៊ុនឡេក ស្ទ័រ (ខេមបូឌា) អ៊ិនដាសស្រ្ទៀល អ៊ិនវេសមិន ឌីវេឡុបមិ៉ន ៦.ក (វិស័យកាត់ដេរ)**
អាសយដ្ឋាន៖ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
**យោង** ៖ លិខិតចុះថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៨៩នាក់ (ស្រី ៣០៣នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៣៨៩នាក់ (ស្រី ៣០៣នាក់) គិតចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣ ដោយកម្មករនិយោជិតត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

១. កម្មករនិយោជិតចំនួន ៣៨១នាក់ (ស្រី ២៩៩នាក់) ដែលព្យួររយៈពេល ១៨ថ្ងៃ ក្នុងខែសីហា ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លារអាម៉េរិក នឹងពីនិយោជកចំនួន ៣០ដុល្លារអាម៉េរិក។
២. កម្មករនិយោជិតចំនួន ៣៨១នាក់ (ស្រី ២៩៩នាក់) ដែលព្យួររយៈពេល ៣០ថ្ងៃ ក្នុងខែកញ្ញា ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លារអាម៉េរិក នឹងពីនិយោជកចំនួន ៣០ដុល្លារអាម៉េរិក។
៣. កម្មករនិយោជិតចំនួន ៣៨១នាក់ (ស្រី ២៩៩នាក់) ដែលព្យួររយៈពេល ១៣ថ្ងៃ ក្នុងខែតុលា ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ២០ដុល្លារអាម៉េរិក នឹងពីនិយោជកចំនួន ១៥ដុល្លារអាម៉េរិក។

ដោយឡែក កម្មករនិយោជិតចំនួន ៨នាក់ (ស្រី ៤នាក់) មិនមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក ម្ចាស់ ឬនាយក** បញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ និងត្រូវទទួលខុសត្រូវបង់ជួសកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរជូនកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់។ ប្រសិនបើបញ្ចប់ការព្យួរកិច្ចសន្យាការងារលើសពី ១លើក **លោក** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះសូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ អង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

**ត.ប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ប៊ុនឈាន**

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត